# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

## ការណែនាំអំពីការចូលរួមរបស់មាតាបិតានៅសាលា

(ដោយសមាគមផ្នែកអប់រំជាតិ)

**<u>បើនិយាយឲ្យចំ តើការចូលរួម នៅសាលា/របស់មាតាបិតា ជាអ្វី?</u>**

**ការចូលរួមក្នុងការអប់រំកូន របស់មាតាបិតា មានន័យថា៖**

- អានឲ្យកូនស្តាប់
- ពិនិត្យមើលកិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ ជារៀងរាល់យប់
- ពិភាក្សាជាមួយគ្រូអំពីការរីកចម្រើនរបស់កូនលោកអ្នក
- ចូលរួមក្នុងសកម្មភាពរបស់ សមាគម មាតាបិតា និង សាលា
- ជួយកូនដើម្បី រៀបចំ និង ធ្វើឲ្យបានតាម ការសិក្សាទូទៅ ដែលពិបាកៗ
- អនុញ្ញាតឲ្យកូនមើលទូរទស្សន៍តែបន្តិចបន្តួចនៅយប់នៃថ្ងៃរៀន
- ធ្វើជាអ្នកជួយគាំទ្រដើម្បីទាមទារឲ្យមានការអប់រំឲ្យកាន់តែប្រសើរឡើង នៅក្នុងសហគមន៍ និង នៅក្នុងរដ្ឋ របស់លោកអ្នក

ឬ គ្រាន់តែធ្វើអ្វីដែលសាមញ្ញ ដូចជាសួរកូនថា «នៅសាលាយ៉ាងម៉េចដែរ ថ្ងៃនេះ?» ប៉ុន្តែត្រូវសួររាល់ថ្ងៃ។ ការធ្វើដូច្នេះ គឺចង់បញ្ជាក់ឲ្យកូនរបស់លោកអ្នកដឹងយ៉ាងច្បាស់ថា ការសិក្សារបស់ពួកគេមានសារៈសំខាន់ណាស់ចំពោះលោកអ្នក ហើយលោកអ្នកចង់ឲ្យពួកគេខំរៀន។

មាតាបិតា និងក្រុមគ្រួសារខ្លះ អាចចូលរួមក្នុងការអំររបស់កូនតាមវិធីផ្សេងៗជាច្រើន។ អ្នកដទៃទៀតប្រហែលជាអាចចូលរួមបានតែសកម្មភាព មួយ ឬ ពីរ តែប៉ុណ្ណោះ។ ទោះជាការចូលរួមរបស់លោកអ្នកមានកម្រិតណាក៏ដោយ ក៏មានសារៈសំខាន់ក្នុងការកែប្រែជិវិតរបស់ក្មេង។

**<u>តើខ្ញុំអាចធ្វើអ្វីខ្លះនៅសាលា?</u>**

ជាមាតាបិតា ឬ ជាមនុស្សពេញវ័យ ដែលជាអ្នកសំខាន់ក្នុងជីវិតរបស់ក្មេង ការចូលរួមរបស់លោកអ្នកក្នុងការអប់រំក្មេងនៅសាលា និងនៅផ្ទះ បង្ហាញឲ្យកូនរបស់លោកអ្នកឃើញថា លោកអ្នកឲ្យតម្លៃដល់ការអប់រំ។ ការរួមសហការរវាងលោកអ្នកនិងគ្រូរបស់កូនលោកអ្នក មានឥទ្ធិពលខ្លាំងក្លាណាស់។

នេះគឺជាវិធីខ្លះដែលលោកអ្នកអាចចូលរួមក្នុងការអប់រំរបស់កូននៅសាលា ក្នុងមួយឆ្នាំៗ៖

- **ជួបជាមួយគ្រូ។** ជម្រាបគាត់អំពី ចំណាប់អារម្មណ៍ និង ចំណូលចិត្ត របស់កូនលោកអ្នក។ ជម្រាបគាត់ឲ្យដឹងពី វិធី និង ពេលវេលា ដែលងាយស្រួលទាក់ទងជាមួយលោកអ្នក។ សួរគាត់អំពីវិធីដែលលោកអ្នកអាច<u>ជួយដល់ការសិក្សារបស់កូនលោកអ្នកនៅផ្ទះ</u>។
- **ណាត់ពេលជាមួយគ្រូដើម្បីទៅមើលថ្នាក់រៀនរបស់កូនលោកអ្នក។** តើក្មេងរវល់ក្នុងការសិក្សា ស្វែងយល់ និង សួរសំណួរ ឬទេ? តើគ្រូទាក់ទាញចិត្តសិស្សឲ្យចង់សិក្សា ឬទេ?
- **ចូលរួម<u>អង្គប្រជុំរវាង គ្រូ និង មាតាបិតា</u>។** ជួបជាមួយគ្រូរបស់កូនលោកអ្នក។ សួរគ្រូថាតើកូនរៀនបានដូចម្តេចដែរ និងពិនិត្យមើលកិច្ចការរបស់កូន។
- **ចូលរួមជាមួយ សមាគមមាតាបិតា និងសាលា ឬ ក្រុមមាតាបិតាផ្សេងៗទៀត។** ទៅចូលរួមក្នុងកម្មវិធីផ្សេងៗនៅសាលា ដូចជា យប់ជួបប្រជុំដំបូងនៅសាលា។ ជាក្រុម លោកអ្នកអាចជួយរកវិធីជួយឲ្យសាលាសម្រេចបានតាមផែនការ។
- **ស្វែងយល់ឲ្យដឹងអំពី ច្បាប់ កាលវិភាគ និង វិន័យ របស់សាលា ថ្មីៗ។** សាកសួរអំពីឱកាសចូលរួមក្នុងការអភិវឌ្ឍន៍ច្បាប់របស់សាលា។

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ

## ការតម្រូវសម្រាប់ការចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យ

**ថ្នាក់មត្តេយ្យគឺជាថ្នាក់ដែលសំខាន់!** ***ការចូលរៀនថ្នាក់មត្តេយ្យបង្កើនឲ្យក្មេងទទួលបានជោគជ័យនៅសាលា!***

សូមកុំចាំដល់ខែកញ្ញាទើបចុះឈ្មោះកូនឲ្យចូលរៀន។ ការចុះឈ្មោះចូលរៀនសម្រាប់ ខែកញ្ញា ២០១៤ សម្រាប់ថ្នាក់មត្តេយ្យ និងថ្នាក់ទីមួយ នឹងប្រព្រឹត្តិទៅរហូតដល់ថ្ងៃសុក្រ ចុងក្រោយបង្អស់នៃខែឧសភា។ មាតាបិតាដែលចុះឈ្មោះកូនឲ្យចូលរៀន ត្រូវយកមកជាមួយនូវ សំបុត្រកំណើត ឯកសារចាក់ថ្នាំបង្ការរោគរបស់ក្មេង និងភស្តុតាងបញ្ជាក់ពីទីកន្លែងរស់នៅ។

១. មានតែក្មេងដែលមានអាយុ៥ឆ្នាំ នៅថ្ងៃ ឬ មុនថ្ងៃ ទី១ ខែកញ្ញា ទើបមានសិទ្ធិចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យ។

២. **ក្មេងដែលមានអាយុ៦ឆ្នាំ ដែលមិនបានទៅរៀនថ្នាក់មត្តេយ្យ** អាចទៅរៀននៅថ្នាក់មត្តេយ្យ ជំនួសថ្នាក់ទី១ តាមការស្នើសុំជាលាយលក្ខណ៍អក្សរពីមាតាបិតា។

៣. កម្មវិធីទាំងអស់គឺពេញមួយថ្ងៃ សម្រាប់ក្មេងថ្នាក់មត្តេយ្យ និងក្មេងដែលចាប់ផ្តើមរៀនថ្នាក់ទី១។

៤. ច្បាប់របស់រដ្ឋផិនស៊ីលវេញ៉ាតម្រូវឲ្យក្មេងចាក់ថ្នាំបង្ការរោគតាមការតម្រូវ។ សូមមើលទំព័រដែលភ្ជាប់មកជាមួយនេះ សម្រាប់ការតម្រូវឲ្យចាក់ថ្នាំបង្ការរោគនៅពេលចូលរៀន នៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

# ការរួបរួមរវាង ក្រុមគ្រួសារ និងសាលា (FAST)

# សម្រាប់ថ្នាក់មត្តេយ្យ

# ការចុះឈ្មោះរបស់ក្រុមគ្រួសារ

ឈ្មោះក្មេង៖_______________________ ប្រុស ☐ ស្រី ☐

មាតា ឬបិតា៖ _______________________

(ជាប់សាច់ញាតិនឹងក្មេងជា) ☐ម្ដាយ ☐ ឪពុក ☐ ជីដូនជីតា ☐ បងប្អូនប្រុស ស្រី ☐ ផ្សេងៗ __________

អាសយដ្ឋាន៖_______________________ លេខតំបន់៖________

ទូរស័ព្ទ៖_______________________

សាលា៖_______________________

គ្រូ៖_______________________

លេខបន្ទប់៖ _______________________

ថ្នាក់៖ មត្តេយ្យ

ខ្ញុំបានទទួលព័ត៌មានអំពីកម្មវិធី FAST សម្រាប់ថ្នាក់មត្តេយ្យ។ ខ្ញុំប្រហែលជាមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងកម្មវិធីនេះជាមួយក្រុមគ្រួសាររបស់ខ្ញុំ។ ខ្ញុំផ្ដល់ការអនុញ្ញាតឲ្យសមាជិកក្រុម FAST ទាក់ទងមកខ្ញុំអំពីការចូលរួមរបស់ក្រុមគ្រួសារខ្ញុំក្នុងកម្មវិធីនេះ។ សមាជិននៃក្រុមនេះអាចជា មាតាបិតាដែលស្ម័គ្រចិត្ត បុគ្គលិករបស់សាលា អ្នកតំណាងសហគមន៍ ឬ ជាដៃគូនៃកម្មវិធីកំសាន្ត (*recreation partner)* ឬ ជាបុគ្គលិករបស់ *Turning Points for Children*។ ខ្ញុំដឹងថា ខ្ញុំអាចទូរស័ព្ទទៅលេខ ២៦៧-២៣៦-១៥៤០ ឬ ២១៥-៤០០-៦៧១៦ បើសិនជាខ្ញុំមានសំណួរអ្វី។

ហត្ថលេខារបស់ មាតាបិតា/អាណាព្យាបាល៖ _______________________ ថ្ងៃខែ៖________________

## ព័ត៌មានអំពីសមាជិកក្រុមគ្រួសាររបស់លោកអ្នក

| ឈ្មោះ | ភេទ ប/ស | ជាប់សាច់ញាតិនឹងក្មេង ខាងលើនេះ ជា | នឹងចូលរួមក្នុង កម្មវិធី FAST? (ចូលរួម/មិនចូល) | សាសន៍ | ភាសា |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

**មានប្រតិកម្មនឹងម្ហូបអាហារអ្វី/ការបារម្ភផ្សេងទៀត៖**

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

## បញ្ជីផ្ទៀងផ្ទាត់សម្រាប់ថ្នាក់មត្តេយ្យ/ *Kindergarten Checklist*

**មាតាបិតា/Parent Name**___________________________________

**ឈ្មោះក្មេង/Child's Name**_________________________ **ថ្ងៃកំណើត/Birth Date** ______________________

ជូនចំពោះ មាតាបិតា/អាណាព្យាបាល៖ / Dear Parent/Guardian:

ក្មេងដែលចេះអ្វីៗដែលមាននៅក្នុងបញ្ជីនេះ នឹងមានមូលដ្ឋានល្អសម្រាប់ការសិក្សានាពេលអនាគត។ ពួកគេនឹងយល់អំពី ការបង្រៀនរបស់គ្រូ និង បរិយាកាសសិក្សា បានពេញលេញ។ ការជួយក្មេងឲ្យចេះអ្វីៗទាំងនេះ មុនពេល និងក្នុងពេល ដែលពួកគេរៀននៅថ្នាក់មត្តេយ្យ គឺជាអ្វីៗដែលត្រូវធ្វើជាបន្ត។ / *Children who learn the skills on this list will have a better foundation for future learning. They will more fully understand the teacher and the learning environment. Helping children learn these skills before and during kindergarten is an ongoing process.*

ឧទាហរណ៍ រួមមាន (សូមគូស ✓ បញ្ជីនេះត្រង់កាឡោនកណ្តាល / *check off the list with ✓in the middle columns)*

| **Does Your Child** | **Yes** ដឹង/ចេះ | **Not Yet** មិនទាន់ដឹង | **តើកូនលោកអ្នក** |
|---|---|---|---|
| 1. Know his/her full name | | | ១. ដឹងឈ្មោះពេញរបស់ខ្លួនឯង |
| 2. Know his/her age | | | ២. ដឹងអាយុខ្លួនឯង |
| 3. Know gender (boy/girl) | | | ៣. ដឹងភេទ (ប្រុស/ស្រី) |
| 4. Know home address and phone number | | | ៤. ដឹងអាស័យដ្ឋានផ្ទះ និងលេខទូរស័ព្ទ |
| 5. Know family member's names (mother, father, grandparents, etc…) | | | ៥. ដឹងឈ្មោះសមាជិកក្រុមគ្រួសារ (ម្តាយ ឪពុក ជីដូនជីតា ។ល។) |
| 6. Know 8 letters of the alphabet and 8 letter sounds | | | ៦. ចេះអក្សរ៨តួ នៃអក្ខរក្រម និងសម្លេងរបស់អក្សរ៨តួរ |
| 7. Know how to hold a book and turn pages | | | ៧. ចេះកាន់សៀវភៅ និងចេះបើកទំព័រសៀវភៅ |
| 8. Point to and name parts of the body | | | ៨. ចង្អុល និងប្រាប់ឈ្មោះ ផ្នែកនៃសរីរាងកាយ |
| 9. Name clothing articles | | | ៩. ប្រាប់ឈ្មោះសម្លៀកបំពាក់ |
| 10. Know names of household items | | | ១០. ស្គាល់ឈ្មោះរបស់របរដែលមាននៅក្នុងផ្ទះ |

| | | | |
|---|---|---|---|
| 11. Identity common animals | | | ១១. ស្គាល់សត្វដែលគេស្គាល់ជាទូទៅ |
| 12. Know names of most foods | | | ១២. ស្គាល់ឈ្មោះម្ហូបអាហារភាគច្រើន |
| 13. Know the words for how things feel (textures) | | | ១៣. ចេះពាក្យសម្រាប់ប្រាប់ពីរបស់ដែល ទន់ រឹង រលោង គ្រើម |
| 14. Know names of coins | | | ១៤. ស្គាល់ឈ្មោះកាក់ (លុយ) |
| 15. Know left and right | | | ១៥. ដឹង ឆ្វេង និង ស្តាំ |
| 16. Know some words that describe things | | | ១៦. ចេះពាក្យខ្លះដែលរៀបរាប់ពីរបស់របរផ្សេងៗ |
| 17. Know some words that tell how things move | | | ១៧. ចេះពាក្យខ្លះដែលប្រាប់ឲ្យដឹងពីការធ្វើចលនា របស់អ្វីមួយ |
| 18. Know something about the places in your neighborhood | | | ១៨. ដឹងអ្វីៗអំពីទីកន្លែងនៅក្នុងតំបន់លោកអ្នក |
| 19. Know the difference between big, bigger, biggest | | | ១៩. ដឹងពីលក្ខណៈខុសគ្នារវាង ធំ ធំជាង ធំបំផុត |
| 20. Know the difference between small, smaller, smallest | | | ២០. ដឹងពីលក្ខណៈខុសគ្នារវាង តូច តូចជាង តូចបំផុត |
| 21. Know how to count 10 things | | | ២១. ចេះរាប់របស់១០មុខ |
| 22. Can point out things that are the same or different | | | ២២. អាចចង្អុលប្រាប់ពីរបស់ដែលដូចគ្នា ឬខុសគ្នា |

| **It would help if your child could:** | **Yes** **ដឹង** | **Not Yet** **មិនទាន់ដឹង** | **វាអាចជួយបើសិនជាកូនលោកអ្នកអាចធ្វើបាន៖** |
|---|---|---|---|
| 23. Respond to his/her name | | | ២៣. ឆ្លើយតបនៅពេលឮគេហៅឈ្មោះខ្លួនឯង |
| 24. Understand speech of others | | | ២៤. ដឹងពីសម្តីរបស់អ្នកដ៏ទៃ |
| 25. Respond to simple questions | | | ២៥. ឆ្លើយតបទៅនឹងសំណួរស្រួលៗ |
| 26. Use short complete sentence | | | ២៦. ប្រើឃ្លាខ្លីៗបានពេញលេញ |
| 27. Follows 2-step directions | | | ២៧. ចេះធ្វើតាមការណែនាំ ដែលមាន២ដំណាក់កាល |
| 28. Tell how he/she feels | | | ២៨. អាចប្រាប់ថាខ្លួនគេមានអារម្មណ៍ដូចម្តេច |
| 29. Ask questions of adults | | | ២៩. សួរសំណួរអំពីមនុស្សពេញវ័យ |
| 30. Relate 2 events of story in sequence | | | ៣០. ដឹងរឿងពីសភាពការណ៍ពីរតាមលំដាប់ |
| 31. Understand that the teacher is in charge in the classroom | | | ៣១. ដឹងថាគ្រូជាអ្នកទទួលខុសត្រូវនៅក្នុងថ្នាក់រៀន |
| 32. Be comfortable with adults while away from home | | | ៣២. មានអារម្មណ៍សុខស្រួលជាមួយមនុស្សពេញវ័យ ខណៈពេលនៅឆ្ងាយពីផ្ទះ |

| **Does your child have these social skills:** | **Yes** **មាន** | **Not Yet** **មិនទាន់មាន** | **តើកូនលោកអ្នកមានចំណេះដឹងផ្នែកទំនាក់ទំនងក្នុងសង្គមទាំងនេះឬទេ៖** |
|---|---|---|---|
| 33. Takes turns | | | ៣៣. ដូរវេនគ្នាម្តងម្នាក់ |
| 34. Shows respect for others and property | | | ៣៤. គោរព អ្នកដទៃ និងទ្រព្យរបស់ផ្សេងៗ |
| 35. Shares toys | | | ៣៥. ចែកគ្នាលេងប្រដាប់ក្មេងលេង |
| 36. Is helpful | | | ៣៦. ចេះជួយ |
| 37. Engage in Cooperative play | | | ៣៧. ចូលរួមក្នុងការលេងជុំគ្នា |
| 38. Now how to say “Please” and “Thank you” | | | ៣៨. ចេះនិយាយថា «សូម/Please » និង «អរគុណ/Thank you» |
| 39. Can sit quietly long enough to play with a toy, do a task, or listen to a story | | | ៣៩. អាចអង្គុយស្ងៀមយូរល្មមដើម្បីលេងជាមួយប្រដាប់ក្មេងលេង ធ្វើកិច្ចការ ឬស្តាប់រឿងអ្វីមួយ |
| 40. Does not argue and fight with other children | | | ៤០. មិនឈ្លោះប្រកែក ហើយមិនវាយតប់ ជាមួយក្មេងដទៃទៀត |
| 41. Accepts disagreements | | | ៤១. ទទួលស្គាល់ការយល់ខុសគ្នា |

| **Does your child have the following self help skills:** | **Yes** **ចេះ** | **Not Yet** **មិនទាន់ចេះ** | **តើកូនលោកអ្នកចេះធ្វើអ្វីៗទាំងនេះក្នុងការជួយខ្លួនឯងឬទេ៖** |
|---|---|---|---|
| 42. Remove and can put on outer clothes | | | ៤២. ចេះដោះ និងពាក់ សម្លៀកបំពាក់ខាងក្រៅ |
| 43. Go to the bathroom without help | | | ៤៣. ទៅបន្ទប់ទឹកដោយមិនបាច់មានគេជួយ |
| 44. Wash and dry own face and hands | | | ៤៤. ចេះលប់មុខ លៀងដៃ និង ជូតមុខ ជូតដៃ ដោយខ្លួននឯង |
| 45. Feeds him/herself | | | ៤៥. ចេះញាំខ្លួនឯង |
| 46. Keeps trying even when task is hard | | | ៤៦. ខិតខំធ្វើជាបន្ត ទោះជាកិច្ចការនោះពិបាកដ៏ដោយ |
| 47. Isn’t easily distracted | | | ៤៧. មិនងាយបែកអារម្មណ៍ |
| 48. Finishes tasks | | | ៤៨. ធ្វើកិច្ចការ ចប់សព្វគ្រប់ |

| **Does your child have these gross motor skills:** | **Yes** **ចេះ** | **Not Yet** **មិនទាន់ចេះ** | **តើកូនលោកអ្នកមានការអភិវឌ្ឍន៍ការប៉ិនប្រសប់ផ្នែកសរីរាងកាយទាំងនេះឬទេ៖** |
|---|---|---|---|
| 49. Walk with ease | | | ៤៩. ដើរបានស្រួលបួល |
| 50. Run lightly on toes | | | ៥០. រត់ស្រាលៗដោយប្រើម្រាមជើង |
| 51. Jump from step using both feet | | | ៥១. លោតជើងពីរចុះ ពីជណ្តើរ |
| 52. Balance on each foot | | | ៥២. ឈរជើងមួយ មានលំនឹង |
| 53. Walk up stairs by alternating feet | | | ៥៣. ឡើងជណ្តើរដោយផ្លាស់ប្តូរជើង |
| 54. Walk downstairs by alternating feet | | | ៥៤. ចេះចុះជណ្តើរដោយផ្លាស់ប្តូរជើង |
| 55. Throw and catch a ball | | | ៥៥. ចេះចោល និងចាប់ បាល់ |